**កោះសន្តិភាព** ឆ្នាំទី៤២ លេខ៦៧០៩ ថ្ងៃព្រហស្បតិ៍ ទី២៣ ខែកក្កដា ឆ្នាំ២០០៩



ទិដ្ឋភាពការចាប់យកដីរបស់ប្រជាពលរដ្ឋ៧០គ្រួសារនៅភូមិក្បាលស្ពាន (រូបថត សុវណ្ណារ៉ា)

# ជម្លោះដីធ្លីសំអាង "ស.ជ.ណ" រៀងខ្លួន ភាគី៧០គ្រួសារសំរុកចូលកាន់កាប់

ក្រុងប៉ោយប៉ែត : កាលពីរសៀលថ្ងៃទី ២១ កក្កដា ប្រជាពលរដ្ឋចំនួន៧០គ្រួសាររស់នៅភូមិក្បាលស្ពាន បាននាំគ្នាសំរុកចូលទៅបោះតង់សង់លំនៅឋាន លើដីទំនាស់មួយកន្លែងស្ថិតនៅក្រោយផ្សាររ៉ា ក្នុងភូមិក្បាលស្ពាន សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ។ តាមការអះអាងពីប្រជាពលរដ្ឋដែលបាននាំគ្នាសំរុកចូលទៅបោះតង់សង់លំនៅឋាននៅលើដីទំនាស់នោះ បាននិយាយឱ្យដឹងថា សកម្មភាពពួកគាត់សំអាងទៅលើស.ជ.ណ លេខ១៣៨៦ ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០០៤ របស់លោកប្រាក់ សុខុន ដែលបានសំរេចឱ្យអាជ្ញាធរខេត្តបន្ទាយមានជ័យប្រគល់ដីទំនាស់នេះឱ្យមកពួកគាត់ទាំង៧០គ្រួសារនេះវិញ ។ អ្នកតំណាងចូលកាន់កាប់នេះ បានបញ្ជាក់ប្រាប់ឱ្យដឹងទៀតថា ចំពោះពួកគាត់ចំនួន៧០គ្រួសារនេះ មានដីទំហំសរុប២៧០ម៉ែត្រ × ៩០ម៉ែត្រ ក្នុងភូមិក្បាលស្ពាននេះ តែត្រូវបានអាជ្ញាធរស្រុករឹបអូសយកដីរបស់ពួកគាត់ ដែលនៅតាំងពីឆ្នាំ២០០០មកម្ល៉េះ ។ បន្ទាប់មកពួកគាត់ទាំង៧០គ្រួសារបានកើតទុក្ខមិនសុខចិត្ត ក៏នាំគ្នាដាក់ពាក្យបណ្តឹងចូលទៅទីស្តីការគណៈរដ្ឋមន្ត្រី ហើយ

ក៏បានទទួលស.ជ.ណ ឱ្យប្រគល់ដីដល់ពួកគាត់វិញផងដែរ ប៉ុន្តែរហូតមកដល់ពេលនេះអាជ្ញាធរខេត្ត-ក្រុងពុំបានអនុវត្ត ទៅតាមស.ជ.ណ ប្រគល់ដីនោះឱ្យមកពួកគាត់៧០គ្រួសារវិញឡើយ ដូច្នេះហើយទើបពួកគាត់ទ្រាំមិនបានក៏សំរេចចិត្ត នាំគ្នាចូលទៅរស់នៅលើដីទំនាស់នេះតែម្តងទៅ ហើយសូមប្រកាសថា បើអាជ្ញាធរមិនរកដំណោះស្រាយទេ គឺពួកគាត់មិន ចាកចេញពីលើដីទំនាស់នេះឡើយ ។ ជុំវិញបញ្ហាប្រជាពលរដ្ឋ៧០គ្រួសារនាំគ្នាសំរុកចូលទៅបោះតង់សង់លំនៅឋាន លើចំណុចដីទំនាស់នោះ មន្ត្រីក្រុងប៉ោយប៉ែតបានឱ្យដឹងថា ចំណុចដីទំនាស់នោះមានភាគីម្ខាងទៀត ដែលមានពលរដ្ឋ ចំនួន៣៥គ្រួសាររស់នៅភូមិក្បាលស្ពានដូចគ្នា គេបានអះអាងថាជាដីរបស់ពួកគេដែរ ហើយចំពោះខាងភាគីពលរដ្ឋ៣៥ គ្រួសារនេះ គឺមានតំណាងចំនួន២នាក់ ១-ឈ្មោះលោកទិត្យ លេក និងម្នាក់ទៀតឈ្មោះស៊ុន ពិសិដ្ឋ ជាតំណាង ហើយគេ ក៏មានស.ជ.ណ លេខ១៥៨៦ ចុះថ្ងៃទី២ វិច្ឆិកា ឆ្នាំ២០០៧ ចេញដោយលោកប្រាក់ សុខុន ដែលទទួលស្គាល់ពួកគេ ដូចគ្នាផងដែរនៅលើចំណុចដីទំនាស់នោះ ។ លោកទិត្យ លេក តំណាងប្រជាពលរដ្ឋ៣៥គ្រួសារបានឱ្យដឹងថា ចំពោះ ប្រជាពលរដ្ឋ៧០គ្រួសារនោះ គឺបានចូលមករំលោភយកដីរបស់ពួកគាត់ ហើយដីរបស់ពលរដ្ឋ៧០គ្រួសារនោះ គឺមិនមែន នៅលើចំណុចដែលពួកគេនាំគ្នាមករស់នៅនេះទេ គឺដីនោះស្ថិតនៅជាប់ព្រំដីរបស់ពួកលោក (ទិត្យ លេខ) ពីខាងលិច ឯណោះទេ។ ចំណែកពលរដ្ឋទាំង៧០គ្រួសារវិញបានឱ្យដឹងថា ចំពោះដីរបស់ពួកគាត់ គឺស្ថិតនៅចំណុចនេះតែម្តង ហើយត្រូវអាជ្ញាធររឹបអូសយកពីពួកគាត់ទៅលក់ ដូច្នោះពេលនេះពួកគាត់មិនអាចស៊ូទ្រាំចាំបានតទៅទៀតទេ ព្រោះបើ គិតទៅទំនាស់ដីនេះមានរយៈពេលជិត១០ឆ្នាំមកហើយគ្មានការដោះស្រាយសោះ។

រហូតមកដល់ពេលនេះស្រាប់តែមានស.ជ.ណមួយទៀត ចេញឱ្យទៅអ្នកផ្សេងនោះ ទើបពួកគាត់សំរេចចិត្ត នាំគ្នាសំរុក ចូលមកកាន់កាប់ដីទំនាស់នេះ ដើម្បីឱ្យអាជ្ញាធររកដំណោះស្រាយតែម្តង ហើយពួកគាត់ប្រកាស ថាបើគ្មានដំណោះ ស្រាយទេនោះ គឺស៊ូស្លាប់មិនចាកចេញពីដីទំនាស់នេះឡើយ ។ ក្រុមប្រជាពលរដ្ឋបានសំណូមពរដល់សម្តេចតេជោ ហ៊ុន សែន ជួយរកយុត្តិធមិដល់ពួកគាត់ទាំងអស់គ្នាផង ។ ទោះបីជាបែបណា លោកទ្រី ណារិន អភិបាលក្រុង ប៉ោយប៉ែត បានប្រាប់កោះសន្តិភាព តាមទូរស័ព្ទឱ្យដឹងថា ចំពោះបញ្ហាប្រជាពលរដ្ឋនាំគ្នាចូលទៅរស់នៅលើចំណុចដី ទំនាស់ ក្នុងភូមិក្បាលស្ពាននោះ គឺពួកគេទាំងសងខាងសំអាងទៅលើស.ជ.ណរៀងៗខ្លួន ដូច្នេះបញ្ហានេះលោកពិបាក ក្នុងការដោះស្រាយខ្លាំងណាស់ ហើយចំពោះប្រជាពលរដ្ឋ៧០គ្រួសារដែលអះអាងថា ជាអ្នកមានដីនៅលើដីទំនាស់នោះ លោកនឹងចាត់ឱ្យសមត្ថកិច្ចជំនាញចុះទៅស្រង់ស្ថិតិ ដើម្បីឱ្យច្បាស់ថាតើពួកគាត់មានឈ្មោះពិតប្រាកដទៅតាមពាក្យ បណ្តឹងនោះដែរឬយ៉ាងណា? ហើយចំពោះដំណោះស្រាយយ៉ាងណានោះ លោកអភិបាលក្រុងបានមានប្រសាសន៍ថា មិនទាន់ហ៊ានសំរេចនៅឡើយទេ រង់ចាំស្រាវជ្រាវបន្តទៀត ។